# រឿង ស្រីក្រោកមាស

ដើមឡើយ មានបុរសម្នាក់ បានទទួលបណ្តាំពីឪពុកប្រដៅថា « កុំឲ្យយកស្រីប្ដីលែង និងស្រីសៅកែ ឲ្យយកតែស្រីក្រមុំ ព្រហ្មចារី និងមេម៉ាយប្ដីស្លាប់ ធ្វើជាប្រពន្ធ ហើយកុំឲ្យយកក្លើនឹងមនុស្សគ្រូបី » តែមិនដូច្នោះ បុរសនោះបានយកស្រី ទាំង ៤ នាក់នោះជាប្រពន្ធ និងយកមនុស្សគ្រូបីជាក្លើ ដើម្បីល្បងមើល ។ ថ្ងៃមួយក្រោកមាសរបស់ស្ដេច ទៅរកស៊ីក្បែរផ្ទះ បុរសនោះ, ឯបុរសនោះ គិតពិសោធមើល ក៏ចាប់ក្រោកមាសនោះយកទៅចងលាក់ទុកក្នុងទ្រុងមួយ ហើយដាក់ចំណី បាយទឹកឲ្យក្រោកនោះស៊ី រួចបុរសយកមាន់គកមួយ ទៅកាប់ធ្វើម្ហូបបរិភោគ ។ ពេលនឹងបរិភោគបុរសនោះ បានយក ប្រពន្ធទាំង ៤ និងក្លើនោះ ទៅបរិភោគទាំងអស់គ្នា ។ កំពុងតែស៊ីក៏ធ្វើជាភ្លក់ និយាយថា «នេះគឺជាសាច់ក្រោកមាសស្ដេច ដែលអញបានលួចកាប់យកមកស៊ី » ។

ក្រោយពីនោះ ដល់បាត់ក្រោក ស្ដេចឲ្យប៉ាវគងសួររកក្រោកនោះ ។ នាងស្រីប្ដីលែង និងនាងស្រីសៅកែ និយាយទៅនាង ក្រមុំ និងនាងប្ដីស្លាប់ថា «ឲ្យប្រាប់ទៅពួកអ្នកប៉ាវគងទៅ ! ថាប្ដីយើងបានលួចកាប់ក្រោករបស់ស្ដេច យកសាច់ស៊ីកុំទៅ ជួយបិទបាំងថ្វី ឲ្យវាងាប់ទៅចុះ ព្រោះវាធ្វើបាបវាយជេរ យើងខ្លាំងណាស់ » ។ ស្រីក្រមុំនិងស្រីប្ដីស្លាប់អង្វរទៅវិញថា « កុំធ្វើបាបប្ដីរបស់ខ្លួនដូច្នោះមិនល្អទេ » ។ ស្រីសៅកែ និងស្រីប្ដីលែងថា «ទោះបីនាងមិនចូលគំនិតនឹងយើង ក៏គង់តែ យើងប្ដឹងអ្នកប៉ាវគងដែរ» ថាហើយ ស្រីទាំងពីរនាក់នោះប្ដឹងអ្នកប៉ាវគងតាមដំណើរថា «ប្ដីខ្លួនលួចក្រោកស្ដេចយកសាច់ ស៊ី» គ្រាន់តែឮដូច្នោះភ្លាម ពួកអ្នកប៉ាវគង ក៏ចាប់យកបុរសនោះ ទៅថ្វាយស្ដេចទូលតាមដំណើរ ។ ស្ដេចឲ្យនាំបុរសនោះ ទៅពិឃាដ , លុះទៅដល់មាត់ទ្វាររាំង អ្នកចាំទ្វារ ពុំព្រមបើកទ្វារ សួរថា «អ្នកនាំមនុស្សទោសនេះមក តើបានជំនុំជម្រះ ហើយឬនៅ?» ហើយបាននិយាយរឿងមួយប្រាប់អ្នកនាំថា :

កាលនោះមានសេដ្ឋីម្នាក់ ចិញ្ចឹមឆ្កែ ៥០០, វេលាយប់មួយ មានចោរជីកឧម្មង្គចូលទៅលួចយកទ្រព្យសម្បត្តិរបស់សេដ្ឋី នោះ ហើយចូលទៅក្នុងឧម្មង្គវិញទាំងអស់ ។ ឆ្កែរបស់សេដ្ឋីដឹង បាននាំគ្នាវាទៅខាំចោរក្នុងឧម្មង្គនោះស្លាប់ទាំងអស់, លុះព្រឹកឡើងមហាសេដ្ឋី ឃើញបាត់ទ្រព្យសម្បត្តិដូច្នោះ នឹកខឹងនឹងឆ្កែថា «មិនចេះចាំរបស់ ក៏ឲ្យគេសម្លាប់ឆ្កែទាំងនោះ ចោលអស់ទៅ» លុះធំអរសោចិ៍ខ្មោចចោរឡើងទៅមើលឃើញចោរស្លាប់ដូច្នោះ ក៏នឹកស្ដាយក្រោយ ។

កំពុងតែនិយាយ ឃើញបម្រើស្ដេច ដែលទ្រង់ព្រះរាជបញ្ជា ឲ្យទៅយកបុរសនោះមកជំនុំជម្រះវិញ ។ លុះស្ដេចសួរបុរស នោះ ពីរឿងសម្លាប់ក្រោកមាស, បុរសក្រាបទូលថាក្រោកនោះ ទូលព្រះបង្គំមិនបានសម្លាប់ទេ គឺបានទុកនៅកន្លែងមួយ ដោយល្អ , ឯសត្វដែលទូលព្រះបង្គំជាខ្ញុំសម្លាប់ ទទួលព្រះរាជទាននោះគឺមាន់គកទេ » ។ ស្ដេចទ្រង់ឲ្យទៅយកក្រោក នោះមកវិញ ហើយទ្រង់លើកលែងទោសបុរសនោះ ។ ឯស្រីទាំងពីរនាក់ដែលប្ដឹងពីបុរសជាប្ដី ថាសម្លាប់ក្រោកនោះ ត្រូវ បុរសជាប្ដីនោះលែងចោលទៅ ។

**ចង់ដឹងផលពិត ត្រូវពិនិត្យរកហេតុ**